ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ០០៧ សរណន

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៦

# សេចក្តីណែនាំ
## ស្តីពី
## ការវាយតម្លៃផ្ទៃក្នុងលើកិច្ចការឃុំ សង្កាត់
## សម្រាប់អាណត្តិទី ១ ឆ្នាំ ២០០២ - ២០០៧

-យោងមាត្រា ៦៦ និង មាត្រា ៦៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

-យោងអនុក្រឹត្យលេខ ២២ អនក្រ បក ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០២ ស្តីពីការផ្ទេរវិមជ្ឈការអំណាច តួនាទី និង ភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់

-ប្រកាសអន្តរក្រសួងលេខ ០៩៨ ប្រក ចុះថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

-ប្រកាសលេខ ១៨៨៤ ប្រក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០២ ស្តីពីប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុងក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំដល់ក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យរៀបចំធ្វើការវាយតម្លៃផ្ទៃក្នុងលើកិច្ចការឃុំ សង្កាត់ សម្រាប់អាណត្តិទី ១ ដូចតទៅ ÷

### ១. គោលដៅ និង វិសាលភាព

ការវាយតម្លៃផ្ទៃក្នុងលើកិច្ចការឃុំ សង្កាត់ មានគោលដៅកែលម្អ និង ពង្រឹងការគ្រប់គ្រងកិច្ចការរបស់ឃុំ សង្កាត់ ដើម្បីបម្រើផលប្រយោជន៍ និង ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់នីមួយៗ ។

ការវាយតម្លៃនេះ គឺជាការវាយតម្លៃផ្ទៃក្នុងរបស់ឃុំ សង្កាត់ ដែលផ្តោតទៅលើលទ្ធផល និង ប្រសិទ្ធភាពនៃកិច្ចអភិវឌ្ឍន៍ និង ការផ្តល់សេវាកម្មរបស់ឃុំ សង្កាត់ ដែលបានអនុវត្តក្នុងអាណត្តិរបស់ខ្លួន ក្នុងវង្វង់ដែនសមត្ថកិច្ចឃុំ សង្កាត់នីមួយៗ ។

### ២. គោលបំណង

ការវាយតម្លៃផ្ទៃក្នុងលើកិច្ចការឃុំ សង្កាត់នេះ មានគោលបំណងដូចខាងក្រោម ÷

- ពិនិត្យ និង បូកសរុបលទ្ធផលនៃការអនុវត្តគម្រោងអភិវឌ្ឍន៍ និងការផ្តល់សេវាកម្មរបស់ឃុំ សង្កាត់។



៦៥

- សិក្សាអំពីប្រសិទ្ធភាព និងផលប៉ះពាល់នៃកិច្ចអភិវឌ្ឍន៍ ការគ្រប់គ្រងរដ្ឋបាល និង ការផ្ដល់សេវាកម្មរបស់ឃុំ សង្កាត់។

- ដើម្បីចែករំលែកបទពិសោធន៍ និង ផ្ដល់អនុសាសន៍ ក្នុងការកែលម្អ និង ពង្រឹងការអនុវត្តតួនាទី ភារកិច្ច ការគ្រប់គ្រងរដ្ឋបាល កិច្ចអភិវឌ្ឍន៍ និង ការផ្ដល់សេវាកម្មរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

## ៣. គោលការណ៍ទូទៅ

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាថាការវាយតម្លៃផ្ទៃក្នុងលើកិច្ចការឃុំ សង្កាត់ អនុវត្តសមស្របតាមគោលការណ៍ ដូចខាងក្រោម ÷

- ឃុំ សង្កាត់នីមួយៗ ជាអ្នកទទួលខុសត្រូវក្នុងការវាយតម្លៃផ្ទៃក្នុងដោយខ្លួនឯង
- មានការចូលរួមពីតំណាងរបស់ប្រជាពលរដ្ឋនៅក្នុងក្រុមវាយតម្លៃផ្ទៃក្នុងរបស់ឃុំ សង្កាត់
- ផ្ដល់ឱកាសដល់សង្គមស៊ីវិល និង អ្នកពាក់ព័ន្ធ ដើម្បីគាំទ្រដំណើរការវាយតម្លៃ
- ការវាយតម្លៃនេះ នឹងផ្ដោតលើដំណើរការទាំងមូលរបស់ឃុំ សង្កាត់
- វិធីសាស្ត្រ និង ឧបករណ៍ត្រូវតែមានលក្ខណៈសាមញ្ញ ដើម្បីឱ្យឃុំ សង្កាត់មានលទ្ធភាពធ្វើបាន។

## ៤. ការបង្កើតគណៈកម្មការវាយតម្លៃផ្ទៃក្នុងឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវចាត់ចែងបង្កើតគណៈកម្មការវាយតម្លៃផ្ទៃក្នុងឃុំ សង្កាត់ ឱ្យបានយ៉ាងយូរត្រឹមថ្ងៃទី **១៥ ខែ កញ្ញា ឆ្នាំ ២០០៦។**

ក្នុងការបង្កើតគណៈកម្មការវាយតម្លៃផ្ទៃក្នុងឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវរៀបចំឱ្យមានកិច្ចប្រជុំដើម្បីពិនិត្យ និង អនុម័តយល់ព្រម។ គណៈកម្មការវាយតម្លៃផ្ទៃក្នុងឃុំ សង្កាត់នេះ មានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| ១-មេឃុំ ចៅសង្កាត់ | ប្រធាន |
| ២-ជនបង្គោលតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ (សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់) | អនុប្រធាន |
| ៣-ជនបង្គោលតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ (មិនមែនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់) | សមាជិក |
| ៤-សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ១ នាក់ | សមាជិក |
| ៥-តំណាងអ្នកទទួលផលចំនួន ២ នាក់ | សមាជិក |
| ៦-តំណាងអង្គការសហគមន៍មូលដ្ឋានចំនួន ២ នាក់ | សមាជិក |
| ៧-ស្មៀនឃុំ សង្កាត់ | លេខាធិការ |

ក្នុងការជ្រើសរើសអ្នកទទួលផលចំនួន ២ នាក់ខាងលើនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិចារណាលើលក្ខខណ្ឌដូចជា ÷

-មានចំណេះដឹង និង បទពិសោធន៍ការងារ

-ជាបុគ្គលដែលមានទីលំនៅអចិន្ត្រៃយ៍ក្នុងឃុំ សង្កាត់ និង មានការគោរពស្រឡាញ់ពីប្រជាពលរដ្ឋ

-ជាអ្នកស្ម័គ្រចិត្ត និង ហ៊ានលះបង់ពេលវេលា សម្រាប់ប្រយោជន៍សាធារណៈ។

ចំពោះការជ្រើសរើសក្រុមសហគមន៍មូលដ្ឋានចំនួន ២ នាក់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើលិខិតអញ្ជើញតំណាងក្រុមសហគមន៍មូលដ្ឋាន ដែលបានអនុវត្តការងារនៅក្នុងឃុំ សង្កាត់របស់ខ្លួនមកប្រជុំ ដើម្បីជ្រើសរើសតំណាងចំនួន ២ នាក់ ឱ្យធ្វើជាសមាជិកគណៈកម្មការវាយតម្លៃផ្ទៃក្នុងឃុំ សង្កាត់។ ក្រុមតំណាងសហគមន៍មូលដ្ឋាន អាចជាភ្នាក់ងារស្ម័គ្រចិត្តភូមិ សមាគមចាស់ជរា សមាគមកសិករ តំណាងក្រុមអ្នកប្រើប្រាស់ទឹក ជនបង្គោលផ្សេងៗនៅក្នុងឃុំ សង្កាត់ ...។ល។

មេឃុំ ចៅសង្កាត់ អាចស្នើសុំដាក់អ្នកជំនួសសមាជិកគណៈកម្មការវាយតម្លៃផ្ទៃក្នុងណាម្នាក់ដែលអវត្តមានក្នុងករណីសមាជិករូបនោះមានធុរៈចាំបាច់ ឬ ប្រការណាមួយ ដែលមិនអាចមកបំពេញការងារបាន។

បន្ទាប់ពីការបង្កើតគណៈកម្មការវាយតម្លៃផ្ទៃក្នុងឃុំ សង្កាត់រួចរាល់ហើយ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើនូវសមាសភាពគណៈកម្មការវាយតម្លៃផ្ទៃក្នុងឃុំ សង្កាត់ជូនដល់អភិបាលខេត្ត ក្រុង តាមរយៈអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង។

**៥. តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់គណៈកម្មការវាយតម្លៃផ្ទៃក្នុងឃុំ សង្កាត់**

គណៈកម្មការវាយតម្លៃផ្ទៃក្នុងឃុំ សង្កាត់ ត្រូវបំពេញការងារដូចខាងក្រោម ÷

- ទទួលខុសត្រូវក្នុងការប្រមូលព័ត៌មាន និង វិភាគទិន្នន័យដែលបានប្រមូល
- រៀបចំរបាយការណ៍វាយតម្លៃ ព្រមទាំងដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិនិត្យ និង ផ្តល់យោបល់
- ផ្សព្វផ្សាយលទ្ធផលដែលរកឃើញជូនដល់សាធារណជន និង អ្នកពាក់ព័ន្ធ
- បញ្ជូនរបាយការណ៍លទ្ធផលនៃការវាយតម្លៃរបស់ខ្លួនមកអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង។

**៦. ដំណើរការ និង វិធីសាស្ត្រនៃការវាយតម្លៃផ្ទៃក្នុងឃុំ សង្កាត់**

គណៈកម្មការវាយតម្លៃផ្ទៃក្នុងឃុំ សង្កាត់ ត្រូវចាប់ផ្តើមអនុវត្តដំណើរការវាយតម្លៃផ្ទៃក្នុងលើកិច្ចការឃុំ សង្កាត់បន្ទាប់ពីទទួលបានការបណ្តុះបណ្តាលចប់សព្វគ្រប់ ហើយត្រូវបញ្ចប់ការងារនេះត្រឹមថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៦។

ក្នុងការវាយតម្លៃផ្ទៃក្នុងនេះ គណៈកម្មការវាយតម្លៃផ្ទៃក្នុងឃុំ សង្កាត់ត្រូវអនុវត្តតាមវិធីសាស្ត្រនៃការវាយតម្លៃផ្ទៃក្នុងដូចមានចែងក្នុងឧបសម្ព័ន្ធទី ១ **"វិធីសាស្ត្រស្តីពីការវាយតម្លៃផ្ទៃក្នុងលើកិច្ចការឃុំ សង្កាត់ សម្រាប់អាណត្តិទី១ ឆ្នាំ ២០០២-២០០៧** " ដូចដែលបានជូនភ្ជាប់មកជាមួយ។

**៧. ការទទួលខុសត្រូវរបស់ខេត្ត ក្រុង**

អភិបាលខេត្ត ក្រុង ដោយមានជំនួយពីអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង ត្រូវតែធានាថាដំណើរការវាយតម្លៃផ្ទៃក្នុងលើកិច្ចការឃុំ សង្កាត់ ក្នុងខេត្ត ក្រុងរបស់ខ្លួន អាចប្រព្រឹត្តទៅបាន និង ដោយរលូន។

ដើម្បីឱ្យការវាយតម្លៃផ្ទៃក្នុងលើកិច្ចការឃុំ សង្កាត់អនុវត្តសមស្របតាមវិធីសាស្ត្រ និង នីតិវិធី ដែលបានកំណត់ អភិបាលខេត្ត ក្រុងត្រូវទទួលខុសត្រូវចាត់ចែង និង ដឹកនាំការងារដូចខាងក្រោម ÷

- ផ្សព្វផ្សាយអំពីសេចក្តីណែនាំស្តីពីការវាយតម្លៃផ្ទៃក្នុងលើកិច្ចការឃុំ សង្កាត់ សម្រាប់អាណត្តិទី ១ របស់ក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ ២០០២-២០០៧

- ណែនាំអំពីការបង្កើតគណៈកម្មការវាយតម្លៃផ្ទៃក្នុងឃុំ សង្កាត់ឱ្យបានសមស្របតាមការកំណត់

- បណ្តុះបណ្តាល និង ពង្រឹងសមត្ថភាពដល់គណៈកម្មការវាយតម្លៃផ្ទៃក្នុងរបស់ឃុំ សង្កាត់

-បូកសរុប និងធ្វើរបាយការណ៍អំពីការបង្កើតគណៈកម្មការវាយតម្លៃផ្ទៃក្នុងឃុំ សង្កាត់មកនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃក្រសួងមហាផ្ទៃ

- ជួយ និង គាំទ្រដល់ដំណើរការវាយតម្លៃផ្ទៃក្នុងរបស់ឃុំ សង្កាត់

- បូកសរុប និង ធ្វើរបាយការណ៍អំពីលទ្ធផលរកឃើញនៃការវាយតម្លៃផ្ទៃក្នុងលើកិច្ចការឃុំ សង្កាត់នៅខេត្ត ក្រុងរបស់ខ្លួន

-ផ្សព្វផ្សាយរបាយការណ៍វាយតម្លៃ និង បញ្ជូនរបាយការណ៍នេះ មកនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃក្រសួងមហាផ្ទៃ

ក្នុងការបូកសរុប និង ធ្វើរបាយការណ៍អំពីលទ្ធផលរកឃើញនៃការវាយតម្លៃផ្ទៃក្នុងឃុំ សង្កាត់ ខេត្ត ក្រុង នីមួយៗ ត្រូវអនុវត្តតាមគោលការណ៍ដូចមានចែងក្នុងឧបសម្ព័ន្ធទី ២ “ **វិធីសាស្ត្របូកសរុបរបាយការណ៍លទ្ធផលនៃការវាយតម្លៃផ្ទៃក្នុងលើកិច្ចការឃុំ សង្កាត់ សម្រាប់អាណត្តិ ទី ១ ឆ្នាំ ២០០២ - ២០០៧** ” ដូចដែលបានជូនភ្ជាប់មកជាមួយ ។

អភិបាលគ្រប់ខេត្ត ក្រុង និងក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ ត្រូវអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**<u>សូមជូនភ្ជាប់មកជាមួយនូវឯកសារ ដូចខាងក្រោម</u>** ៖

-ឧបសម្ព័ន្ធទី ១ : វិធីសាស្ត្រស្តីពីការវាយតម្លៃផ្ទៃក្នុងលើកិច្ចការឃុំ សង្កាត់ សម្រាប់អាណត្តិទី ១ ឆ្នាំ ២០០២-២០០៧ ចំនួន ១ ច្បាប់ ។

-ឧបសម្ព័ន្ធទី ២ : នីតិវិធីបូកសរុបរបាយការណ៍ នៃលទ្ធផលការវាយតម្លៃផ្ទៃក្នុងលើកិច្ចការឃុំ សង្កាត់ សម្រាប់អាណត្តិទី ១ ឆ្នាំ ២០០២-២០០៧ ចំនួន ១ ច្បាប់ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**<u>ចម្លងជូន</u>** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
  “ ដើម្បីជូនជ្រាប ”
- សាលាខេត្ត ក្រុង
- សាលាឃុំ សង្កាត់
  “ ដើម្បីមុខការ ”
- ឯកសារ កាលប្បវត្តិ